# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ទីក្រុងគ្រីស្ទានសាន់ (ន័រវែស) ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍
## សូមដោះលែងលោក អៀ ចាន់ណា ដោយគ្មានលក្ខខណ្ឌ

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** ពិនិត្យឃើញថា សកម្មជនព្រំដែន និងជាសមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក **អៀ ចាន់ណា** គ្មានកំហុសដូចការចោទប្រកាន់ ពីសំណាក់សាលាដំបូងរាជធានីភ្នំពេញទេ។ ការចាប់ឃុំខ្លួនលោក **អៀ ចាន់ណា** ជាការធ្វើឡើងក្រោមហេតុផលនយោបាយ ខណៈពេលលោក ទៅចូលរួមយុទ្ធនាការឃោសនាបោះឆ្នោតឃុំសង្កាត់ ជាមួយគណបក្សភ្លើងទៀន។ ការចាប់ឃុំខ្លួននេះ ជាការរំលោភរដ្ឋធម្មនុញ្ញយ៉ាងធ្ងន់ធ្ងរ។

លោក **អៀ ចាន់ណា** មានសិទ្ធិពេញលេញចូលរួមសកម្មភាពនយោបាយ សកម្មភាពសង្គម ក្នុងនាមជាពលរដ្ឋខ្មែរ និងជាសកម្មជននយោបាយ ដូចពលរដ្ឋ និងអ្នកនយោបាយឯទៀតដែរ ដោយស្របតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញ មាត្រា៣៥ *«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ»*។

ដោយរំលឹកឡើងវិញថា រដ្ឋាភិបាលកម្ពុជា បានធ្វើសច្ចាប្រណិធាន និងប្តេជ្ញាយ៉ាងមុតមាំ គោរពខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញរបស់ខ្លួន គោរពកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ និងគោរពអនុសញ្ញា កតិការសញ្ញា សន្ធិសញ្ញា កិច្ចព្រមព្រៀង របស់អង្គការសហប្រជាជាតិ អ.ស.ប. (UN) និងអង្គការអន្តរជាតិនានា ដែលជាមាគ៌ារបស់កម្ពុជា ធានាការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋពេញលេញ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមអំពាវនាវដល់តុលាការរាជធានីភ្នំពេញ និងរដ្ឋាភិបាលនៃលោក **ហ៊ុន សែន** ដោះលែងលោក **អៀ ចាន់ណា** ដោយគ្មានលក្ខខណ្ឌ, ម្លាក់ចោលបទចោទនានាទៅលើសកម្មជននយោបាយ សកម្មជនសង្គម និងទម្លាក់បទចោទលើសំណុំរឿងលោក **កឹម សុខា** ដើម្បីស្តារស្ថានភាពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឡើងវិញ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**
**ប្រធាន**

**ម៉ែន ណាត**

CWCI Cambodia, address: Senterveien 54, Apartment 112, 4790 Lillesand (town), NORWAY